ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងព្រហ្មទណ្ឌលេខ ៧៨០
ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៩
សាលក្រមលេខ ៨០ "ខ"
ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២១

# ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២១
វេលាម៉ោង ០៨ និង៣០នាទី ព្រឹក ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៨០ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១៩ ដែលមានជនជាប់ចោទ ៖

១. ឈ្មោះ [redacted] **សាវ៉ុន** ភេទប្រុស អាយុ ២៩ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ឆ្នាំង មានអាសយដ្ឋានភូ[redacted] ខេត្តកំពង់ឆ្នាំង នៅលីវ ឪពុកឈ្មោះ [redacted] វួន "រស់" ម្តាយឈ្មោះ [redacted] សុខ "រស់" កម្រិតវប្បធម៌ ថ្នាក់ទី៧ ទោសពីមុន គ្មាន ។

ក្រៅឃុំ តាមដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៤៦៩ ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០២០

២.ជនជាប់ចោទឈ្មោះ [redacted] **វ៉ន** ភេទប្រុស អាយុ ៦៤ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ឆ្នាំង មានអាសយដ្ឋានភូ[redacted] ខេត្តកំពង់ឆ្នាំង នៅលីវ ឪពុកឈ្មោះ [redacted] អ៊ឹម "រស់" ម្តាយឈ្មោះ [redacted] ហ៊ឹម "ស្លាប់" ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ពីបទ **ក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលគិរី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦២៩ មាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ ។

លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀង ភេទស្រី អាយុ៦០ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានភូមិកំពង់ខ្លាញ់ ឃុំជលសារ ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ។

លោក [redacted] មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤០៥៩/២០២០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

បានឃើញ ដីកាដំណោះស្រាយ (បញ្ជូនសំណុំរឿងទៅជំនុំជម្រះ)លេខ ៨៦៧ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ

កាលពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៨ ឈ្មោះ [redacted] សាវ៉ុន និងឈ្មោះ [redacted] វ៉ូន បានយកគ្រឿងចក្រទៅធ្វើសកម្មភាពឈូសឆាយ ទម្លាយភ្លឺលើដីស្រែត្រង់ចំណុចកំពង់ខ្លាញ់ ឃុំជលគិរី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ហៀង ដោយឈ្មោះ [redacted] សាវ៉ុន ណិងឈ្មោះ [redacted] វ៉ូន សំអាងលើកិច្ចសន្យាទិញលក់ដែលមានស្នាមកោសលុបសរសេរបំពេញបន្ថែម ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ [redacted] វ៉ូន បានឆ្លើយថា៖ ដើមឡើយខ្លួនមានដីទំហំ៤៨០ម៉ែត្រ ពេលខ្លួនធ្វើម្ចាស់ដីប្រាប់ថាចុះតែ ៤៥០ម៉ែត្រ បានហើយ ពេលធ្វើសំបុត្រនៅឃុំ ម្ចាស់ដីកែដាក់ ៤៨០ម៉ែត្រ វិញខ្លួនសួរ គាត់ថាមិនអីទេ។ ក្រោយមកកូនខ្លួនទៅធ្វើប្លង់ដី ខ្លួនទិញដីពីឈ្មោះ [redacted] វុទ្ធី ទំហំ ៤៨០ម៉ែត្រគុណ ១០០ម៉ែត្រ ខ្លួនទិញពីឈ្មោះ [redacted] វុទ្ធី អត់បានដឹងថាមានឯកសារ ឬអត់ទេ ខ្លួនទិញអត់បានដឹងតម្លៃប៉ុន្មានទេ ដីនេះ ឈ្មោះ [redacted] វុទ្ធី ជាអ្នកប្រាប់ខ្លួន ពេលទិញដីកូនខ្លួនឈ្មោះ [redacted] សាវ៉ូន។ ខ្លួនអត់ចាំថាបានផ្តិតមេដៃលើកិច្ចសន្យាឬក៏អត់ទេ។ ខ្លួនសំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ដល់រូបខ្លួនផង ។

ជនជាប់ចោទឈ្មោះ [redacted] **សាវ៉ុន** បានឆ្លើយថា: កាលពីថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៧ ឪពុកខ្លួនទិញដីពីឈ្មោះ [redacted] វុទ្ធី ទំហំ៤៨០ម៉ែត្រ បណ្តោយ ១០០ម៉ែត្រ តម្លៃ១៨លានរៀល បានផ្តិតមេដៃលើកិច្ចសន្យាទិញលក់។ លុះដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ ម្ចាស់ដីអង្វរឪពុកខ្លួនថា

បងយកតែ ៤៥០ម៉ែត្រ គុណ ១០០ម៉ែត្រ សិនទៅ ពេលនោះមេភូមិកែពី ៤៨០ម៉ែត្រ ទៅ៤៥០ម៉ែត្រ វិញ។ ខ្លួនសំណូមពរសុំឱ្យតុលាការលើកលែងការចោទប្រកាន់ដល់រូបខ្លួនផង ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ហៀង** បានឆ្លើយថា៖ ខាងគាត់ (ឈ្មោះ [redacted] វ៉ូន) ទិញពីឈ្មោះ [redacted] វុទ្ធី ហើយភ្ជួរលើដំណាំខ្លួនអស់ ខ្លួនក៏ប្តឹងទៅអធិការស្រុក និងភូមិបាលស្រុក ថាបានចូលដីទំហំ ២០ម៉ែត្រ គុណ ១៣០ម៉ែត្រ ដីខ្លួនជាប់នឹងដីឈ្មោះ [redacted] វ៉ូន ដីនេះមានទំហំ ៣៥០ម៉ែត្រ គុណ ១០០ម៉ែត្រ មិនចូលដីខ្លួនទេ ប៉ុន្តែគាត់មានទំហំរហូតដល់ ៤៨០ម៉ែត្រ គុណ ១០០ម៉ែត្រ ប៉ះចូលដីរបស់ខ្លួនខាងជើង២០ម៉ែត្រ ខាងត្បូង៥៤ម៉ែត្រ និងបណ្តោយ១៣០ម៉ែត្រ ខ្លួនដឹងដោយសារខ្លួនបានចុះវាស់ ទើបឃើញចូល។ ខ្លួនបានឃើញកិច្ចសន្យាទិញលក់ដីរបស់ឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] វ៉ូន មានសរសេរបន្ថែមពី ៣៥០ម៉ែត្រ ទៅ ៤៥០ម៉ែត្រ វិញ ពាក់ព័ន្ធនឹងការទិញលក់ ខ្លួនមិនបានចូលរួមទេ ។

សាក្សីឈ្មោះ [redacted] **វុទ្ធី** បានឆ្លើយថា៖ ខ្លួនបានលក់ដីឱ្យឈ្មោះ [redacted] វ៉ូន ទំហំ ១០០ម៉ែត្រ បណ្តោយ ៣៥០ម៉ែត្រ មិនចាំថ្ងៃខែ។ ដំបូងលក់ខែវស្សា ៤៥០ម៉ែត្រ វាស់ជាក់ស្តែងទំហំ ៣៥០ ម៉ែត្រ ជាដីព្រៃ ក្នុងការទិញលក់ ឈ្មោះ [redacted] វ៉ូន ជំពាក់ ៣លានរៀល ហើយឈ្មោះ [redacted] វ៉ូន ប្តឹងឱ្យ ខ្លួនយកដីគេបន្ថែម។ ខ្លួនបានទិញលក់ផ្តិតមេដៃនៅផ្ទះមេភូមិលើដីទំហំ ៣៥០ម៉ែត្រ គុណ ១០០ ម៉ែត្រ ហើយអត់បាននិយាយថាកែទេ ។

សាក្សីឈ្មោះ [redacted] **រិន** បានឆ្លើយថា៖ ដំបូងខ្លួនធ្វើកិច្ចសន្យាកក់ប្រាក់ឱ្យឈ្មោះ [redacted] វ៉ូន លើដី ទំហំ ៤៨០ ម៉ែត្រ គុណ ១០០ម៉ែត្រ តម្លៃ១៨លានរៀល ក្រោយធ្វើដីស្អាត ទំហំ ៣៥០ម៉ែត្រ គុណ ១០០ម៉ែត្រ រវាងឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] វ៉ូន ខ្លួនបានផ្តិតមេដៃ និងសូត្រឱ្យស្តាប់ ទំហំ ៣៥០ ម៉ែត្រ គុណ១០០ម៉ែត្រ ធ្វើកិច្ចសន្យាអត់មានកែ ៤៥០ម៉ែត្រទេ។ ពេលធ្វើកិច្ចសន្យាអត់ឮនិយាយថាខុសទំហំដី ឬកែទេ ។

សាក្សីឈ្មោះ [redacted] **ឡឿន** បានឆ្លើយថា៖ ខ្លួនបានចុះហត្ថលេខាលក់ដីរបស់ឈ្មោះ [redacted] វុទ្ធី ទំហំ ៣៥០ម៉ែត្រ គុណ ១០០ម៉ែត្រ។ ខ្លួនបានទៅពិនិត្យផ្ទាល់គឺជាដីអាស្រ័យផលទេ រវាងឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] វ៉ូន លក់ទិញប្រគល់ប្រាក់ឱ្យតែ ១៥លានរៀល ទេ នៅជំពាក់ ៣លានរៀលទៀត សន្យាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨ ប្រគល់ឱ្យ ៣លានរៀល នៅថ្ងៃទី១០ មិនចាំខែ ឆ្នាំ២០១៨ ឈ្មោះ [redacted] សារ៉ុន បានយកត្រាក់ទ័រឈូសដីរបស់ឈ្មោះ [redacted] ហៀង។ ចំពោះដីលក់នោះទំហំ ៣៥០ម៉ែត្រ គុណ ១០០ ម៉ែត្រ អត់មានកែទេ ឬកោសលុបទេ និងបានធ្វើកិច្ចសន្យាត្រឹមត្រូវមានតែមួយច្បាប់ប៉ុណ្ណោះ ។

សាក្សីឈ្មោះ [redacted] **ឈុន** បានឆ្លើយថា៖ ឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] វ៉ូន មានទំនាស់ជាមួយគ្នាលើដីទំហំ ៣៦អាទេ ខ្លួនដោះស្រាយមិនត្រូវគ្នា ក្រោយមកឈ្មោះ [redacted] វុទ្ធី យកលិខិតពីមេភូមិឱ្យខ្លួនចុះហត្ថលេខា ខ្លួនមិនទាន់បានចុះ ខ្លួនក៏បានហៅឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] ហៀង មក ឈ្មោះ [redacted] វុទ្ធី ថាខ្លួនលក់តែដីអត់មានទំនាស់ទេ។ ក្រោយមកខ្លួនក៏បានចុះហត្ថលេខា បន្ទាប់មករយៈពេល ០១ឆ្នាំទើបមានទំនាស់ ចំពោះឯកសារពុំមានកោសលុបទេ។ នៅពេលចុះហត្ថលេខាខ្លួនអាន និងអត់មានសរសេរជាន់ ឬកោសលុបទេ។ ឈ្មោះ [redacted] វុទ្ធី ជាអ្នកកាន់ឯកសារឱ្យខ្លួនចុះហត្ថលេខាពុំមានការកោសលុបទេ ការទិញលក់ដីពុំមានកូពីទុកទេ មានតែចុះលេខ។ ការទិញលក់ត្រូវមានម្ចាស់ព្រំទាំងសងខាងទើបខ្លួនព្រមចុះហត្ថលេខា ។

សាក្សីឈ្មោះ [redacted] **វ៉ាន់ស៊ីម** បានឆ្លើយថា៖ ក្រោយទិញហើយ អានកិច្ចសន្យាថា ៣៥០ម៉ែត្រ គុណ ១០០ម៉ែត្រ តែម្ចាស់អ្នកទិញស្រែកថាមិនមែនទេ គឺ ៤៥០ម៉ែត្រ ខ្លួនដឹងតែប៉ុណ្ណឹង ។

សាក្សីឈ្មោះ [redacted] **គឿន** បានឆ្លើយថា៖ ចំពោះកិច្ចសន្យាលក់ដីរវាងឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] វ៉ូន ធ្វើនៅផ្ទះរបស់ឈ្មោះ [redacted] វុទ្ធី ខ្លួនបានផ្តិតមេដៃ ទំហំ ៤៨០ម៉ែត្រ គុណ ៤៥០ម៉ែត្រ តែកន្ទុយដី ៣០ម៉ែត្រ កំពុងមានទំនាស់ជាមួយឈ្មោះ [redacted] ហៀង។ ពេលធ្វើកិច្ចសន្យាមេភូមិសរសេរចំនួន ៣៥០ម៉ែត្រ អ្នកទិញប្រាប់ថា មិនមែនទេ ៤៥០ម៉ែត្រ មេភូមិក៏បន្ថែមដាក់លេខ ៤ តែម្តង។

សាក្សីឈ្មោះ [redacted] **ជឿន** ជាមន្ត្រីនគរបាលខេត្តបានឆ្លើយថា៖ ខ្លួនត្រូវបានមេឱ្យចុះសាកសួរ និងធ្វើកំណត់ហេតុ ដីទំហំ៤៥០ ម៉ែត្រខ្លួនសួរឈ្មោះ [redacted] វុទ្ធី ពីរឿងទិញលក់រវាងឈ្មោះ [redacted] វ៉ូន ទំហំ ៤៥០ម៉ែត្រ កំពុងមានទំនាស់រវាងឈ្មោះ [redacted] ហៀង និងឈ្មោះ [redacted] វ៉ូន នៅឡើយ ។

**មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា**

ដីមានទំហំ ៣៥០ម៉ែត្រ គុណ ១០០ម៉ែត្រ ទេ ដោយមាននៅក្នុងសៀវភៅកំណត់ហេតុ និងមានស្នាមផ្តិតមេដៃ។ តាមចម្លើយរបស់មេឃុំថា ពេលចុះហត្ថលេខា បើមានកោសលុប គាត់មិនចុះហត្ថលេខាទេ ហើយមេភូមិក៏ថាមានតែ ៣៥០ម៉ែត្រ គុណ ១០០ម៉ែត្រ។ ដូចនេះសុំឱ្យតុលាការមេត្តាផ្តន្ទាទោសតាមច្បាប់ និងសុំទាមទារសំណងចំនួន ៤០.០០០.០០០(សែសិបលាន) រៀល ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា**

ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនៅក្នុងសវនាការ ដែលមានជនជាប់ចោទឈ្មោះ [redacted] **សាវ៉ុន** និងឈ្មោះ [redacted] **វ៉ូន** ដែលត្រូវបានចោទប្រកាន់ពីបទ **ក្លែងបន្លំឯកសារសាធារណៈ/ប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលគិរី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៩



Scanned with CamScanner

មាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។ ហេតុដូចនេះប្ដឹងសុំតុលាការដូចដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរដដែល ។

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា**

ឆ្លងកាត់នាពេលសវនាការឃើញថា តុលាការចោទប្រកាន់លើឈ្មោះ [redacted] **សាវ៉ុន** និងឈ្មោះ [redacted] **វ៉ុន** ឃើញថា ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ប៉ុន្តែសាក្សី នៅពេលនេះមានអ្នកឆ្លើយមិនពិត ខ្លួនសូមបញ្ជាក់ថា សាក្សីឈ្មោះ [redacted] គឿន គាត់ឆ្លើយតាំងពីលើកដំបូង គឺទិញលក់ ៤៥០ម៉ែត្រ តែលោកមេភូមិសរសេរតែ ៣៥០ម៉ែត្រ តែកែលេខ៤ ជាន់លើលេខ៣។ ដើមបណ្ដឹងរដ្ឋប្បវេណីគាត់លក់ ៤៥០ម៉ែត្រ តែពេលនេះគាត់ឆ្លើយតែ ៣៥០ម៉ែត្រ វិញព្រោះថាកូនក្ដីខ្លួនបាន ទិញដីទំហំ ៤៥០ម៉ែត្រ គុណ ១០០ម៉ែត្រ មិនមែន ៣៥០ម៉ែត្រ គុណ ១០០ម៉ែត្រទេ ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំតុលាការលើកលែងការចោទប្រកាន់លើកូនក្ដីរបស់ខ្លួនផង។

ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់ចម្លើយសាក្សី

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្ដុតាង

ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

១. កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ឈ្មោះ [redacted] សាវ៉ុន និងឈ្មោះ [redacted] វ៉ូន បានយកគ្រឿងចក្រទៅធ្វើសកម្មភាពឈូសឆាយ ទម្លាយភ្លឺលើដីស្រែត្រង់ចំណុចកំពង់ខ្លាញ់ ឃុំជលគិរី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ហៀង ដោយឈ្មោះ [redacted] សាវ៉ុន និងឈ្មោះ [redacted] វ៉ូន សំអាងលើកិច្ចសន្យាទិញលក់ដែលមានស្នាមកោសលុបសរសេរបំពេញបន្ថែម ប្រាកដមែន ។

២. ថ្វីត្បិតតែជនជាប់ចោទឈ្មោះ [redacted] **សាវ៉ុន** និងឈ្មោះ [redacted] **វ៉ូន** បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ ប៉ុន្តែចម្លើយនេះគ្រាន់តែជាចម្លើយដោះសារប៉ុណ្ណោះ ព្រោះផ្ទុយតាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ អ៊ុង ហៀង ដែលស្របនឹងចម្លើយរបស់សាក្សីឈ្មោះ [illegible]

ឈ្មោះ [redacted] វុទ្ធី បានឆ្លើយថា កិច្ចសន្យាទិញលក់ដីមានទំហំ ៣៥០ ម៉ែត្រ មិនមែន ៤៥០ម៉ែត្រ ទេ ដែលចម្លើយទាំងនេះមានភាពស្របនឹងភស្តុតាងផ្សេងៗទៀត ដែលមាននៅក្នុងសំណុំរឿងអាចបញ្ជាក់គួរឱ្យតុលាការជឿបានថា ជនជាប់ចោទ ពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ ប្រាកដមែន ។

៣. ជនជាប់ចោទ ជានីតិជន និងជាសមត្ថជនដែលមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ បានពោលគឺពុំមានភស្តុតាងណាមួយបញ្ជាក់ មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

៤. ជនជាប់ចោទឈ្មោះ [redacted] **សាវ៉ុន** ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ និងឈ្មោះ [redacted] វ៉ុន ភេទប្រុស អាយុ៦៤ឆ្នាំ សញ្ជាតិខ្មែរ ត្រូវបានបញ្ជូនទៅជំនុំជម្រះ ពីបទ **ក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលគិរី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦២៩ មាត្រា៦៣០ នៃក្រមព្រហ្មទណ្ឌ ។

៥.សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **សាវ៉ុន** និងឈ្មោះ [redacted] **វ៉ុន** បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការសមគំនិតក្នុងអំពើប្រើប្រាស់អំពើ **ក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រាកដមែន ។

៦. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សាវ៉ុន ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ និងឈ្មោះ [redacted] វ៉ុន ភេទប្រុស អាយុ៦៤ឆ្នាំ សញ្ជាតិខ្មែរ ពីបទ ក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅភូមិកំពង់ខ្លាញ់ ឃុំជលគិរី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៩ មាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

៧. អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយ សាធារណៈ សន្តិសុខសង្គម ។

០៨. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ហៀង** បានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល គប្បីតុលាការពិនិត្យ ពិភាក្សា ពិចារណា និងសម្រេចទៅតាមភាពជាក់ស្តែង និងសមរម្យ ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោស ៖

ក. ឈ្មោះ [redacted] **សាវ៉ុន** ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ

ខ. ឈ្មោះ [redacted] វ៉ុន ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ

ពីបទ **ក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារសាធារណៈក្លែង** ប្រព្រឹត្តនៅភូមិកំពង់ខ្ចាញ់ ឃុំជលគិរី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

២. ឱ្យឈ្មោះ [redacted] **សាវ៉ុន** និងឈ្មោះ [redacted] **វ៉ុន** រួមគ្នាបង់ការខូចខាត និងជម្ងឺចិត្តចំនួន ៥.០០០.០០០ (ប្រាំលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ហៀង** ។ ច្រានចោលការទាមទារលើពីនេះ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២១ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

បានឃើញ ថ្ងៃព្រហស្បតិ៍ ១២កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** កំពង់ឆ្នាំង, ថ្ងៃទី ២៥ ខែមីនា ឆ្នាំ ២០២១

**ក្រឡាបញ្ជី**

[redacted] [redacted]